## ទិដ្ឋភាពទូទៅ

ការអភិវឌ្ឍន៍តំបន់ទីក្រុងនៅក្នុងតំបន់អាស៊ីអគ្នេយ៍ កំពុងរីកដុះដាលយ៉ាងឆាប់រហ័សនៅក្នុងទីក្រុងធំៗ ដែលជាទូទៅមានទីតាំងនៅក្នុងតំបន់ទំនាបលិចទឹកក្បែរទន្លេធំៗ ។ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធបូមទឹក និងសេវាកម្មអនាម័យសំរាប់ទីក្រុងទាំងនោះ រួមជាមួយការជីកយកដីពីតំបន់ជុំវិញក្រុងដើម្បីចាក់បំពេញកន្លែងសំណង់ និងធ្វើទំនប់ការពារទឹកជំនន់ផងនោះ បាននាំអោយតំបន់ជាយក្រុងប្រែក្លាយជាតំបន់ដីសើម ដែលជានិច្ចកាលជាកន្លែងសំរាប់សំអាតទឹកសំណល់ និងផលិតអាហារជលផល។ តំបន់ដីសើមទាំងនោះរួមមាន ទន្លេ បឹងបួរ និងប្រព័ន្ធប្រលាយទឹក នៅជាយក្រុង ដែលតែងតែផ្តល់ មធ្យោបាយដល់ការចោលសំណល់របស់មនុស្ស គឺជាកន្លែងផលិតអាហារ និងបង្កើតប្រាក់ចំណូលយ៉ាងសំខាន់សំរាប់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។ ទោះបីផលប្រយោជន៍នៃតំបន់ដីសើមជាយក្រុង ទាំងនោះត្រូវបានគេមើលឃើញពិតមែន ប៉ុន្តែតំលៃរបស់វាមិនទាន់ត្រូវបានគេស្រាវជ្រាវ និង វាស់វែង ជាមួយនឹងផលប៉ះពាល់នៃការបំពុល ការផ្លាស់ប្តូរ និងនគររូបនីយកម្មនៅឡើយ ។ ការសិក្សាជាច្រើនបានធ្វើឡើងកន្លងមក ដែលពតិមានភាគច្រើនផ្តោតលើបញ្ហាបច្ចេកទេសនោះ បានទទួលបរាជ័យក្នុងការដោះស្រាយបញ្ហាស្មុគស្មាញរបស់អនាគតនៃប្រព័ន្ធផលិតកម្មអាហារជលផលនៅជាយក្រុង។ ឧបសគ្គចំបងចំពោះការងារនយោបាយ និងការងារគ្រប់គ្រងតំបន់ជាយក្រុង ដែលកំពុងរីកដុះដាលយ៉ាងរហ័សនៅក្នុងតំបន់អាស៊ីនោះ គឺកង្វះខាតពតិមានសមស្របអំពីអ្នកពាក់ព័ន្ធ និងអវត្តមាននៃការវាយតំលៃដោយមិនលំអៀងលើគ្រោះថ្នាក់សុខភាពសារធារណៈ ភាពរកបានអាហារ និងជីវភាពរស់នៅ។ កង្វះខាតពតិមានស្តីពីប្រព័ន្ធទាំងនោះ គឺខុសពីចំណេះដឹងដែលបានចងក្រងទុកក្នុងឯកសារស្តីអំពីការកែច្នៃប្រើប្រាស់ឡើងវិញ នូវសំណល់រឹង និងរាវនៅក្នុងវិស័យកសិកម្ម។ ជាងនេះទៅទៀត តំបន់ជាយក្រុងដែលតែងតែវិវត្តផ្លាស់ប្តូរ ទាមទារអោយមានការធ្វើទំនាក់ទំនង និង ការសហការ រវាងអ្នករស់នៅជាយក្រុង អ្នកវិទ្យាសាស្ត្រ អ្នកធ្វើផែនការ និង អ្នកនយោបាយ ដើម្បីឆ្លើយតបទៅនឹងបំរែបំរួលយ៉ាងរហ័ស និងប្រឈមមុខនឹង គ្រោះថ្នាក់របស់ប្រព័ន្ធផលិតកម្មអាហារជលផលនៅជាយក្រុង ក្នុងខណៈដែលវាកំពុងប្រឈមមុខនឹងការ ប្រឹងប្រែងផ្គត់ផ្គង់តំរូវការរបស់មនុស្ស រួមនឹងការប្រកួតប្រជែងជាមួយនឹងការដណ្តើមផ្ទៃដី និង ផ្ទៃទឹក នៅតំបន់ជាយក្រុង។ ដោយមានការគិតគូរពីភាពប្រថុយប្រថាន និងឧបសគ្គចំពោះនិរន្តភាពនៃប្រព័ន្ធផលិតកម្មអាហារជលផលនៅតំបន់ជាយក្រុងដែលបានលើកឡើងខាងលើ និងតួនាទីក្នុងការផលិតអាហារ និងសេវាកម្មសំអាតទឹកសំណល់ គំរោងនេះបានធ្វើឡើងដើម្បីឆ្លើយតបទៅនឹងកង្វះខាតចំណេះដឹងស្តីពីស្ថានភាព និងសក្តានុពលភាពរបស់ប្រព័ន្ធទាំងនោះ។ វាត្រូវបានគេរំពឹងថា នឹងផ្តល់ជាចំណេះដឹង អំពី

តួនាទី និងផលប៉ះពាល់របស់ប្រព័ន្ធផលិតកម្មទាំងនោះ ក្នុងចំណោមទីក្រុងទាំង ៤ ដែលបានសិក្សារួមមាន ភ្នំពេញ បាងកក ហូជីមិញ និង ហាណូយ ជាពិសេសការផ្តល់ការងារ ទ្រព្យធន ការកាត់បន្ថយការបំពុល ការផ្គត់ផ្គង់អាហារ និង ការប្រើប្រាស់ និង សំអាតទឹកសំណល់។ម្យ៉ាងទៀត ការសិក្សាក៏បានធ្វើទៅលើ អន្តរទំនាក់ទំនងរវាងប្រព័ន្ធទាំងនោះ អ្នកផលិត អ្នកប្រើប្រាស់ និង ស្ថាប័នដែលចូលរួមពាក់ព័ន្ធ។ ចំណេះ ទាំងនេះនឹងរួមចំនែកក្នុងការបង្កើនការយល់ដឹងពីតំលៃរបស់ប្រព័ន្ធផលិតកម្មអាហារជាយក្រុងទាំងនោះ មិនសំរាប់តែសហគមន៏ប៉ុណ្ណោះទេ តែសំរាប់ទីក្រុងទាំងមូល និង នាំទៅរកការធ្វើផែនការ និង អភិវឌ្ឍន៏ តំបន់ទីក្រុងដោយមានតុល្យភាព និងសនិទានភាព ខណៈនោះដែរ ជំរុញអោយមានយុទ្ធសាស្រ្តគ្រប់គ្រង ប្រសើរឡើង ដែលនឹងការពារផលប្រយោជន៏របស់ប្រព័ន្ធផលិតកម្មចំពោះអ្នកទទួលផលទាំងឡាយ។